# លោកជំទាវ ជូ ប៊ុនអេង អញ្ជើញជាគណៈអធិបតីបើក និងបិទវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់ អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប នៅសាលាខេត្តកណ្តាល ថ្ងៃទី២៦-២៨ ខែកញ្ញា ឆ្នាំ២០១៦



(កណ្តាល)៖កាលពីព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ នៅសាលប្រជុំសាលាខេត្តកណ្តាល មានបើកវគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របរយៈពេលបីថ្ងៃគឺថ្ងៃទី២៦-២៨ ខែកញ្ញា ឆ្នាំ២០១៦ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងជាប្រធាន គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ) មានការអញ្ជើញចូលរួមពីគ្រូឧទ្ទេស បណ្តាថ្នាក់ដឹកនាំមន្ទីរជុំវិញខេត្ត អភិបាលស្រុក អធិការស្រុកក្រុង និងអង្គភាព ស្ថាប័នពាក់ពាន់មួយចំនួនទៀត។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅ និងកោតសរសើរចំពោះ **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ) ព្រមទាំងបណ្តាគ្រូឧទ្ទេស និងសិក្ខាកាមទាំងអស់ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ហើយសូមឲ្យសិក្ខាកាមទាំងអស់ត្រូវយកចិត្តទុកដាក់ ខិតខំស្វែងយល់ រាល់មេរៀនដែលគ្រូឧទ្ទេសបានបង្ហាត់បង្រៀនជូននាពេលនេះ ដើម្បីងាយស្រួលនៅពេលយើងបានបញ្ចប់វគ្គទៅ យើងនឹងអនុវត្តបានល្អក្នុងការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងដើម្បីបង្ហាត់បង្ហាញបន្តដល់មន្ត្រីនៅក្នុងមូលដ្ឋានបន្ថែមទៀត ឲ្យកាន់តែយល់ច្បាស់អំពីបញ្ហាជួញដូរមនុស្សនៅកម្ពុជា។





**លោកជំទាវ ជូ ប៊ុនអេង** បានលើកឡើងពីផលលំបាកចំពោះពលករមួយចំនួនធំ ដែលកំពុងតែធ្វើការងារនៅក្រៅប្រទេស ខ្លះត្រូវបានគេបង្ខិតបង្ខំឲ្យធ្វើការងារគ្មានពេលសម្រាក ខ្លះទៀតត្រូវថៅកែមិនបើកប្រាក់

ខែឲ្យ និងជាប់បំណុលគេរហូត។ ជាពិសេសពលករនេសាទត្រីនៅសមុទ្រពុំដែលបានឡើងគោក បើឈឺវិញរហូតដល់ស្លាប់ ត្រូវថៅកែយកទៅភ្លាសេក្នុងទឹកកករួចបោះចូលក្នុងសមុទ្រតែម្តង មួយចំនួនទៀតត្រូវបានសមត្ថកិច្ចថៃចាប់ដាក់គុក គ្មានដំណឹងអ្វីសោះដល់គ្រួសារ ចំណែកពលករទ្រុឌទ្រោមគ្មានកម្លាំង អសមត្ថភាពការងារ ត្រូវគេបញ្ជូនមកប្រទេសវិញដោយ គ្មាននៅសល់ប្រាក់កាសអ្វីសោះក្នុងខ្លួន ដែលធ្វើឲ្យក្រុមគ្រួសារ និងសង្គមជាតិទទួលរងនូវផលលំបាកយ៉ាងធ្ងន់ធ្ងរ។





នៅថ្ងៃបញ្ចប់វគ្គបណ្តុះបណ្តាលនាពេលនេះ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មានប្រសាសន៍ថ្លែងអំណរគុណចំពោះ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងគ្រូឧទ្ទេស ព្រមទាំងសិក្ខាកាមទាំងអស់ ដែលបានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល ចំនួនបីថ្ងៃនេះទទួលបាននូវលទ្ធផលយ៉ាងល្អប្រសើរ។ **លោកជំទាវ** មានប្រសាសន៍ផ្តាំផ្ញើចំពោះសិក្ខាកាមដែលបានសិក្សារៀនសូត្រទាំងអស់ នៅថ្ងៃនេះក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល ត្រូវប្តេជ្ញាចិត្តខិតខំជួយអប់រំបន្ត និងធ្វើការបង្ការទប់ស្កាត់រាល់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៅក្នុងមូលដ្ឋាន របស់ខ្លួនផង។



**លោកជំទាវ ជូ ប៊ុនអេង** បានមានប្រសាសន៍ជូនពរចំពោះ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត គ្រូឧទ្ទេស សិក្ខាកាម និងក្រុមការងារសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្នុងវគ្គបណ្តុះបណ្តាលនេះជួបប្រទះពុទ្ធពរទាំងបួនប្រការ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

